# សាលាកប័ត្រព័ត៌មាន
# យុទ្ធសាស្ត្របណ្តឹងផ្លូវច្បាប់ប្រឆាំងនឹងការចូលរួមជាសាធារណៈនៅកម្ពុជា
# ចាប់ពីខែមករា ឆ្នាំ២០២៣ ដល់ខែធ្នូ ឆ្នាំ២០២៣

**ទិដ្ឋភាពរួម៖** សាលាកប័ត្រព័ត៌មាននេះស្វែងយល់ពីការប្រើប្រាស់យុទ្ធសាស្ត្របណ្តឹងផ្លូវច្បាប់ប្រឆាំងនឹងការចូលរួម ជាសាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា ("ប្រទេសកម្ពុជា") ក្នុងអំឡុងពេលចាប់ពីខែមករា ឆ្នាំ២០២៣ ដល់ ខែធ្នូ ឆ្នាំ ២០២៣។ យុទ្ធសាស្ត្របណ្តឹងផ្លូវច្បាប់ប្រឆាំងនឹងការចូលរួមជាសាធារណៈ ("យុទ្ធសាស្ត្របណ្តឹងផ្លូវច្បាប់") ត្រូវបានប្រើប្រាស់ចំនួន ៣៩ ដង ក្នុងរយៈពេលពេញមួយឆ្នាំ២០២៣។ ការអនុវត្តជាទៀងទាត់នៃយុទ្ធសាស្ត្របណ្តឹងផ្លូវច្បាប់ពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា និងភាគីទីបីបានធ្វើឱ្យប៉ះពាល់ដល់សេរីភាពខាងការបញ្ចេញមតិនិងបន្ទុចបង្អាក់ការចូលរួមរបស់ពលរដ្ឋ។ ផលប៉ះពាល់អំពីការខូចខាតដោយសារយុទ្ធសាស្ត្របណ្តឹងផ្លូវច្បាប់នៅកម្ពុជាអាចមើលឃើញតាមរយៈករណីសិក្សាដែលបានបង្ហាញនៅខាងក្រោមនេះ។ ទិន្នន័យដែលបានបង្ហាញនៅក្នុងសាលាកប័ត្រព័ត៌មាននេះ ត្រូវបានចងក្រងដោយគម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន ("គម្រោង") ដែលជាការអនុវត្តរួមគ្នាដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា សមាគមអាដហុក និងមជ្ឈមណ្ឌលសាមគ្គីភាព។

## តើអ្វីគឺជាយុទ្ធសាស្ត្របណ្តឹងផ្លូវច្បាប់ប្រឆាំងនឹងការចូលរួមជាសាធារណៈ?

- **យុទ្ធសាស្ត្រ** = អ្វីមួយដែលបានធ្វើរួច, ដោយចេតនានិងល្បិចកលដើម្បីឱ្យសម្រេចគោលដៅជាក់លាក់ណាមួយ
- **បណ្តឹងផ្លូវច្បាប់** = វិវាទរដ្ឋប្បវេណីឬព្រហ្មទណ្ឌ ដែលបញ្ជូនទៅស្ថាប័នតុលាការ
- **ប្រឆាំង** = ជំទាស់នឹងអ្វីមួយ
- **ការចូលរួម** = ចូលរួមចំណែកក្នុងការធ្វើអ្វីមួយ
- **សាធារណៈ** = ប្រជាជនទាំងមូល

**យុទ្ធសាស្ត្របណ្តឹងផ្លូវច្បាប់** គឺជាបណ្តឹងដែលធ្វើឡើងដោយចេតនាដើម្បីយកមកប្រើប្រាស់ដើម្បីបំបាក់ទឹកចិត្ត បំភិតបំភ័យ រំខាន បង្អាក់ ឬបង្ខោចទ្រព្យជនជាប់ចោទ បំបិទសំឡេង ប្រឆាំង ការរិះគន់ឬការមិនយល់ស្របរបស់ពួកគេ។ ជាទូទៅយុទ្ធសាស្ត្របណ្តឹង គឺជាបណ្តឹងរដ្ឋប្បវេណីដែលប្តឹងដោយភាគីទីបី។ ដោយឡែក នៅកម្ពុជាយុទ្ធសាស្ត្របណ្តឹងផ្លូវច្បាប់ត្រូវបានរាជរដ្ឋាភិបាល ឬតុលាការប្រើប្រាស់ជាញឹកញាប់ក្នុងទម្រង់ជាការដាក់ទោសព្រហ្មទណ្ឌ ដូចជា ការកោះហៅមកសាកសួរ ឬដាក់ឱ្យជាប់បណ្តឹងអាជ្ញា។

## គោលបំណងនៃយុទ្ធសាស្ត្របណ្តឹងផ្លូវច្បាប់ប្រឆាំងនឹងការចូលរួមជាសាធារណៈ

**យុទ្ធសាស្ត្របណ្តឹងផ្លូវច្បាប់** ផ្តោតគោលដៅជាក់លាក់ទៅលើតែសមាជិកសកម្មក្នុងសហគមន៍ដែលប្រើប្រាស់សេរីភាពបញ្ចេញមតិ។ យុទ្ធសាស្ត្របណ្តឹងផ្លូវច្បាប់នេះតែងត្រូវបានស្ថាប័នមានអំណាចដូចជារាជរដ្ឋាភិបាល ឬបុគ្គលមានទ្រព្យសម្បត្តិយកមកប្រើប្រាស់ដើម្បីបំបិទសំឡេងរិះគន់និងបំបាក់ទឹកចិត្តដល់ប្រជាពលរដ្ឋនៅក្នុងការចូលរួមក្នុងសង្គម។ យុទ្ធសាស្ត្របណ្តឹងផ្លូវច្បាប់នេះបានធ្វើឱ្យការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងសង្គមធ្លាក់ចុះដោយសារតែការភ័យខ្លាចមានការជាប់ពន្ធនាគារ និងខ្លាចបង្កជាបន្ទុកធ្ងន់ធ្ងរផ្នែកថវិកាក្នុងការចំណាយលើសេវា ច្បាប់និងប្រាក់ពិន័យផ្សេងៗ។ យុទ្ធសាស្ត្របណ្តឹងផ្លូវច្បាប់នេះត្រូវបានយកមកប្រើប្រាស់ជាយុទ្ធសាស្ត្រមួយក្នុង ការបំភិតបំភ័យបុគ្គលទាំងឡាយដូចជា តួអង្គសង្គមស៊ីវិល ថ្នាក់ដឹកនាំសហគមន៍ អ្នកសារព័ត៌មាន អ្នកផ្សាយព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្សឱ្យមានការភ័យខ្លាចនិងស្ងៀមស្ងាត់។

# យុទ្ធសាស្ត្របណ្តឹងផ្លូវច្បាប់ប្រឆាំងនឹងការចូលរួមជាសាធារណៈនៅកម្ពុជា




នៅក្នុងឆ្នាំ២០២៣ គម្រោងបានកត់ត្រា ៣៩[1] ករណីដែលចាត់ទុកជា ករណីយុទ្ធសាស្ត្របណ្តឹងផ្លូវច្បាប់ លើមនុស្សចំនួន ១២៧ នាក់ ដែលបែងចែកជា ៧ ប្រភេទផ្សេងៗគ្នា។ ការប្រើប្រាស់យុទ្ធសាស្ត្របណ្តឹងផ្លូវច្បាប់ ភាគច្រើនគឺកំណត់មុខសញ្ញាលើសកម្មជននយោបាយ ឬ អ្នកនយោបាយជំទាស់ អ្នកសារព័ត៌មាន និងសមាជិកសហគមន៍ដីធ្លី។ ៣១% នៃករណី (មានមនុស្ស៥២នាក់) គឺជាបណ្តឹងលើសកម្មជននយោបាយឬអ្នកនយោបាយ ពាក់ព័ន្ធករណីបង្ហោះឬចែករំលែកមតិយោបល់អំពីការបោះឆ្នោតសកលឆ្នាំ២០២៣។ បន្ថែមពីនេះ ២១% (មានមនុស្ស៩នាក់) គឺជាបណ្តឹងជំទាស់មកលើអ្នកសារព័ត៌មាន បន្ទាប់ពីរាយការណ៍ ឬបកស្រាយរឿងអំពើពុករលួយ ឬបញ្ហារសើប។







យុទ្ធសាស្ត្របណ្តឹងផ្លូវច្បាប់ត្រូវបានប្រើប្រាស់តាមខែនីមួយៗក្នុងឆ្នាំ២០២៣។ គួរកត់សម្គាល់ថា មានការប្រើប្រាស់យុទ្ធសាស្ត្របណ្តឹងផ្លូវច្បាប់ចំនួន១០ករណី ក្នុងអំឡុងពេលបោះឆ្នោតជាតិ ក្នុងខែកក្កដា ឆ្នាំ២០២៣ ដែលជាខែមានករណីកើតបណ្តឹងច្រើនជាងគេ។ ទន្ទឹមនឹងនេះ ករណីភាគច្រើន គឺរាជរដ្ឋាភិបាលឬតុលាការ[2] ជាអ្នកប្រើបណ្តឹងនេះ ព្រមទាំងកំណត់មុខសញ្ញាលើបុគ្គលចម្រុះ។




គម្រោងបានកត់ត្រាបុគ្គលចំនួន ១២៧ នាក់ទទួលរងយុទ្ធសាស្ត្របណ្តឹងផ្លូវច្បាប់ក្នុងទម្រង់នៃការដាក់ទណ្ឌកម្មព្រហ្មទណ្ឌ ដែលក្នុងនោះមនុស្សចំនួន ៦១ នាក់ ត្រូវបាន កោះហៅឱ្យចូលខ្លួននៅប៉ុស្តិ៍នគរបាល ឬតុលាការ

[1] ករណីដែលចាត់ទុកជាយុទ្ធសាស្ត្របណ្តឹងផ្លូវច្បាប់ គឺជាករណីដែលពាក់ព័ន្ធនឹងការប្តឹងប្រឆាំងនឹងបុគ្គលដែលអនុវត្តសេរីភាពជាមូលដ្ឋានដោយស្របច្បាប់ ធ្វើឡើងដើម្បីបំបាក់ទឹកចិត្ត បំភិតបំភ័យ ប្រឈមមុខ រំខានដល់សកម្មភាពរបស់ពួកគេ ឬធ្វើឱ្យបង្ខាចហិរញ្ញវត្ថុ បំបិទការជំទាស់ ការរិះគន់ ឬការមិនយល់ស្របរបស់ពួកគេ។

[2] ក្នុងករណីខ្លះនៃយុទ្ធសាស្ត្របណ្តឹងផ្លូវច្បាប់ ត្រូវបាននាំមកដោយភាគីទីបី រួមទាំងនិយោជក ឧកញ៉ា ឬអ្នកមានអំណាចផ្សេងទៀត។

ដើម្បីបំភ្លឺករណីរបស់ពួកគេ។ យោងតាមការកត់ត្រារបស់គម្រោង មនុស្សចំនួន ៦៧ នាក់ ត្រូវបានចោទប្រកាន់ ដែលភាគច្រើនជាសកម្មជននយោបាយ អ្នកនយោបាយ គណបក្សជំទាស់ ឬអ្នកសារព័ត៌មាន។[3]

**ស្របពេលដែលការចោទប្រកាន់ពីបទព្រហ្មទណ្ឌត្រូវបានប្រើប្រាស់ជាញឹកញាប់ ចំនួនយុទ្ធសាស្ត្របណ្ដឹងផ្លូវច្បាប់ដែលបានផ្ដន្ទាទោសក្នុងរយៈពេល ១២ខែនេះ មានតួលេខប្រហាក់ប្រហែលនឹងឆ្នាំមុន។ នៅក្នុងឆ្នាំ២០២២ មានការប្រើប្រាស់យុទ្ធសាស្ត្របណ្ដឹងផ្លូវច្បាប់ ៣៧ ករណី មកលើមនុស្ស ៧៩នាក់ បើប្រៀបធៀបទៅនឹងបុគ្គលចំនួន១២៧ នាក់ ក្នុងឆ្នាំ២០២៣ ដែលក្នុងចំណោមនោះ ៥៣ ត្រូវបានកាត់ទោស។ នេះបង្ហាញឱ្យឃើញថា ការប្រើយុទ្ធសាស្ត្របណ្ដឹងផ្លូវ ច្បាប់គឺជាឧបករណ៍បំបាក់ទឹកចិត្ត និងរារាំងបុគ្គលផ្សេងៗក្នុងការអនុវត្តសេរីភាពមូលដ្ឋានរបស់ខ្លួនប៉ុណ្ណោះ។ យុទ្ធសាស្ត្របណ្ដឹងផ្លូវច្បាប់មានគោលដៅការពាររាជរដ្ឋាភិបាលនិងបុគ្គលមានអំណាចពីការរិះគន់ឬជំទាស់។ ហេតុទាំងនេះ នាំឱ្យមានការចាប់ខ្លួនបុគ្គលជាច្រើន និងការជំនុំជម្រះរឿងក្ដីព្រហ្មទណ្ឌទៀតសោតមានរយៈពេលយូរមិនកំណត់ ព្រមទាំង ចំណាយធនធានជាច្រើន ហើយជារឿយៗករណីទាំងនោះតែងមានការឃុំខ្លួនបណ្ដោះអាសន្នជាច្រើនខែឆ្នាំ។**

## <u>ករណីសិក្សា</u>

យុទ្ធសាស្ត្របណ្ដឹងផ្លូវច្បាប់ មិនអនុវត្តតែចំពោះតែបុគ្គលមួយចំនួននោះទេ។ ករណីសិក្សាខាងក្រោមបង្ហាញ ពីយុទ្ធសាស្ត្របណ្ដឹងផ្លូវច្បាប់ ដែលបានកំណត់មុខសញ្ញាមកលើ សហគមន៍ សហជីព/សហព័ន្ធ អ្នកសារព័ត៌មាន និងសកម្មជន។




**ករណីទី១៖ ក្រុមសកម្មជនដីធ្លីឬអ្នកតំណាងសហគមន៍ដីធ្លី**

នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៣ នគរបាលបានបញ្ឈប់សកម្មជនដីធ្លីមួយក្រុមមកពីខេត្តកោះកុង នៅពេលដែលពួកគេកំពុងធ្វើដំណើរដើម្បីទៅដាក់ញត្តិទៅក្រសួងយុត្តិធម៌នៅរាជធានីភ្នំពេញ ដើម្បីទាមទារឱ្យទម្លាក់បទចោទលើសកម្មជនចំនួន ៣០នាក់ មកពី ៥ សហគមន៍។ នគរបាលបានរារាំងរថយន្តចំនួន ៤ គ្រឿងដែលកំពុងធ្វើដំណើរទៅរាជធានីភ្នំពេញ និងឃាត់ខ្លួនអ្នកភូមិចំនួន ១១ នាក់ ដោយចោទប្រកាន់ ១០នាក់ពីបទញុះញង់ តាមមាត្រា ៤៩៤ និង ៤៩៥ នៃក្រមព្រហ្មទណ្ឌ។ សកម្មជនម្នាក់ត្រូវបានដោះលែងឱ្យនៅក្រៅឃុំដោយមានលក្ខខណ្ឌរឹតត្បិត។ ចំណែកឯសកម្មជន ៩នាក់ទៀត (ក្នុងនោះមានទារកអាយុ១៨ខែម្នាក់ដែលជាកូនរបស់សកម្មជន) កំពុងជាប់ឃុំក្នុងពន្ធនាគារខេត្តកោះកុង។ កាលពីថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៣ តុលាការខេត្តកោះកុង បានចោទប្រកាន់ពួកគេពីបទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ និងបទបរិហារកេរ្តិ៍ជាសាធារណៈ ហើយផ្ដន្ទាទោសឱ្យជាប់ពន្ធនាគាររយៈពេល១ឆ្នាំ បូករួមនឹងការពិន័យជាប្រាក់សរុបចំនួន ៤០លានរៀល ដើម្បីសងទៅដើមបណ្ដឹងឧកញ៉ា ហេង ហ៊ុយ។ នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៣ សាលាឧទ្ធរណ៍បានសម្រេច ឱ្យពួកគេពីរួចផុតពីបទចោទប្រកាន់ញុះញង់ហើយបានលុបចោលការផ្ដន្ទាទោសដាក់ពន្ធនាគារ ប៉ុន្តែប្រកាសតម្កល់ការផ្ដន្ទាទោសពីបទបរិហារកេរ្តិ៍ និងបន្ថយប្រាក់សំណងមកត្រឹម១០លានរៀល។ ទោះយ៉ាងណា តុលាការបានប្រកាសបង្គាប់ឱ្យជនជាប់ចោទទាំងពីរ[4] បង់ប្រាក់ពិន័យ ៤ លានរៀលក្នុង១នាក់ផងដែរ។

[3]ចំនួនសរុបនៃបុគ្គលដែលទទួលទណ្ឌកម្មព្រហ្មទណ្ឌអាចលើសពីចំនួនមនុស្សសរុប ១២៧ នាក់ ដែលក្នុងនោះមនុស្សម្នាក់អាចត្រូវទទួលរងទណ្ឌកម្មផ្នែកព្រហ្មទណ្ឌច្រើនជាងមួយ។

[4] អ្នកទាំងពីរត្រូវបានចោទប្រកាន់ពាក់ព័ន្ធនឹងការប្រមូលផ្ដុំនៅមុខក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ កាលពីឆ្នាំ២០១៩ ដើម្បីដាក់ញត្តិស្វែងរកដំណោះស្រាយសមស្របមួយជុំវិញជម្លោះដីធ្លីដ៏រ៉ាំរ៉ៃរបស់ពួកគេ។

**ករណីទី២៖ បុគ្គលិក សហជីព/សហព័ន្ធសហជីព**



កាលពីថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២៣ សាលាដំបូងខេត្តកណ្តាលបានចេញដីកាកោះតាមពាក្យបណ្តឹងរបស់តំណាងក្រុមហ៊ុនស្តារឡៃថ៍ មកលើកម្មករនិយោជិតចំនួន១០នាក់ ក្នុងនោះមានស្ត្រីម្នាក់។ បណ្តឹងនេះត្រូវបានធ្វើឡើងក្រោមបទចោទ "ញុះញង់ឱ្យមានការរើសអើង" និង "ការបរិហារកេរ្តិ៍" ។ តុលាការបានបង្គាប់ឱ្យបុគ្គលទាំង១០នាក់ចូលខ្លួនបំភ្លឺនៅព្រឹកថ្ងៃទី២១ ខែសីហា ឆ្នាំ២០២៣។ ពាក្យបណ្តឹងបានធ្វើឡើង បន្ទាប់ពីកម្មកររាប់រយនាក់តវ៉ា ទាមទារឱ្យក្រុមហ៊ុនគោរពលក្ខខណ្ឌការងារ និងដកប្រធានរដ្ឋបាលចេញពីក្រុមហ៊ុន។ ទោះជាយ៉ាងណាករណីខាងលើនេះ តំណាងក្រុមហ៊ុនបានដកពាក្យបណ្តឹងវិញបន្ទាប់ពីមានការចចារ។



រូបភាព RFA

**ករណីទី៣៖ សកម្មជននយោបាយ/អ្នកនយោបាយ**

នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៣ សាលាដំបូងរាជធានីភ្នំពេញបានឃុំខ្លួនថ្នាក់ដឹកនាំគណបក្សជំទាស់ និងជាអនុប្រធានគណបក្សភ្លើងទៀន លោក ថាច់ សេដ្ឋា បន្ទាប់ពីការសាកសួរនៅសាលាដំបូងរាជធានីភ្នំពេញ គាត់ក៏ត្រូវបានបទចោទប្រកាន់លើកទី២ តាម មាត្រា ៤៩៤ និង ៤៩៥ នៃក្រមព្រហ្មទណ្ឌក្រោម "បទញុះញង់" ការចោទសួរនេះទាក់ទង នឹងសុន្ទរកថារបស់លោកនៅពេលទៅជួបជាមួយអ្នកគាំទ្រគណបក្សភ្លើងទៀននៅប្រទេសជប៉ុន កាលពីចុងឆ្នាំ២០២២ ។



កាលពីថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ សមាជិក និងសកម្មជនបក្សជំទាស់ចំនួន ១៧ នាក់ ត្រូវបានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតរាជធានីភ្នំពេញ (គជ/ខប)ពិន័យជាប្រាក់ លុបឈ្មោះចេញពីបញ្ជីបោះឆ្នោត និងហាមឈរឈ្មោះបោះឆ្នោត។ គួរកត់សម្គាល់ថា ពួកគេត្រូវបានចោទប្រកាន់ផ្អែកតាមមាត្រាថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់បោះឆ្នោត បន្ទាប់ពីបានរិះគន់តាមបណ្តាញសង្គមហ្វេសបុកអំពីការបោះឆ្នោតឆ្នាំ២០២៣។

**ករណីទី៤៖ អ្នកសារព័ត៌មាន**



រូបភាពហ្វេសបុក

លោក ផាត់ ហ៊ន អ្នកសារព័ត៌មាន និងចាងហ្វាងសារព័ត៌មានអនឡាញ KH Plus News ត្រូវបាននគរបាលខេត្តស្វាយរៀង កោះហៅមកសាកសួរនៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២៣ បន្ទាប់ពីបានផ្សាយបន្តផ្ទាល់វីដេអូ កាលពីថ្ងៃទី២១ ខែសីហា ឆ្នាំ២០២៣ នៅលើទំព័រហ្វេសប៊ុករបស់លោក អំពីភាពមិនប្រក្រតីនៃដំណើរការសាងសង់ផ្លូវ ស្ថិតក្នុងឃុំដូង ស្រុករមាសហែក និងសង្កាត់ប្រេកម្ទេស ក្រុងបាវិត។ ពាក្យបណ្តឹងបានធ្វើឡើងដោយរដ្ឋបាលខេត្តស្វាយរៀងដោយចោទថាបាន "បរិហាកេរ្តិ៍ជាសាធារណៈ" រយៈពេលតែ៣ថ្ងៃប៉ុណ្ណោះបន្ទាប់ពីលិខិតចំហរបស់រដ្ឋបាលខេត្តស្វាយរៀងដែលព្រមានចាត់វិធានការផ្លូវច្បាប់។ រដ្ឋបាលខេត្តស្វាយរៀងជាអ្នកដាក់ពាក្យបណ្តឹងនេះដោយចោទប្រកាន់គាត់ពីបទ "បរិហារកេរ្តិ៍ជាសាធារណៈ"។ ទាក់ទិននឹងករណីនេះ នៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៣ លោកក៏ត្រូវបានតុលាការខេត្តស្វាយរៀង កោះហៅមកសាកសួរ ជុំវិញករណីបណ្តឹងបទ "បរិហារកេរ្តិ៍ជាសាធារណៈ"។




កាលពីថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៣ នគរបាលខេត្តបន្ទាយមានជ័យបានចាប់ខ្លួនចាងហ្វាងសារព័ត៌មានខ្មែរជាយដែន លោក អ៊ុង ថាប់រ៉ាង និងបញ្ជូនទៅឃុំខ្លួននៅពន្ធនាគារខេត្តបន្ទាយមានជ័យ ពីបទបរិហារកេរ្តិ៍ជាសាធារណៈ និងញុះញង់ឱ្យមានការរើសអើង។ សំណុំរឿងនេះកើតឡើងបន្ទាប់ពីមានការចុះផ្សាយអត្ថបទស្តីពីអំពើពុករលួយរបស់មន្ត្រីសាលាក្រុងប៉ោយប៉ែត និងមន្ត្រីពន្ធដារខេត្ត។[5]

## អនុសាសន៍

ការប្រើប្រាស់យុទ្ធសាស្ត្របណ្តឹងផ្លូវច្បាប់បានកើនឡើងជាលំដាប់នៅប្រទេសកម្ពុជាជាមួយនឹងបណ្តឹងផ្លូវច្បាប់ជាច្រើនទៀតពី សំណាក់ភាគីទីបី ក៏ដូចជារាជរដ្ឋាភិបាលកម្ពុជាខ្លួនឯង។ យុទ្ធសាស្ត្របណ្តឹងផ្លូវច្បាប់បានប៉ះពាល់ដល់សិទ្ធិមនុស្ស និង មិនលើកទឹកចិត្តប្រជាពលរដ្ឋក្នុងការចូលរួមក្នុងសង្គមព្រមទាំងនាំទៅរក វប្បធម៌ស្ងៀមស្ងាត់ដោយការកម្រិតសេរីភាពខ្លួនឯង។ ដើម្បីទប់ស្កាត់ករណីយុទ្ធសាស្ត្របណ្តឹងផ្លូវច្បាប់រាជរដ្ឋាភិបាលគួរ៖

I. ជម្រុញឱ្យមានច្បាប់ដែលហាមប្រាមយុទ្ធសាស្ត្របណ្តឹងផ្លូវច្បាប់ប្រឆាំងនឹងការចូលរួមជាសាធារណៈ ហើយច្បាប់នោះមានចែងពីការផ្តន្ទាទោសដល់បុគ្គលឬស្ថាប័នដែលប្រើប្រាស់យុទ្ធសាស្ត្របណ្តឹងផ្លូវច្បាប់ត្រឹមឆ្នាំ២០២៦។

II. ពិនិត្យនិងវិសោធនកម្មក្រមព្រហ្មទណ្ឌជាពិសេសបទល្មើសបរិហាកេរ្តិ៍និងការញុះញង់ឱ្យស្របទៅតាមក្របខ័ណ្ឌច្បាប់សិទ្ធិមនុស្សអន្តរជាតិ ដូចដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័នត្រឹមឆ្នាំ២០២៦។

III. ផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីនគរបាលនិងមន្ត្រីតុលាការឱ្យយល់ដឹងពីយុទ្ធសាស្ត្របណ្តឹងផ្លូវច្បាប់ប្រឆាំងនឹងការចូលរួមជាសាធារណៈ និងការរំលឹកឡើងវិញ២ដងក្នុង១ឆ្នាំ។

IV. បង្កនិងបង្កើតបរិយាកាសល្អសម្រាប់អ្នកការពារសិទ្ធិមនុស្ស អ្នកសារព័ត៌មានឯករាជ្យ និងសកម្មជនដែលអនុញ្ញាតឱ្យអ្នកទាំងនោះអាចធ្វើការ និងសកម្មភាពស្របច្បាប់របស់ខ្លួន ស្របតាមអនុសាសន៍ដែលរាជរដ្ឋាភិបាលបានទទួលយកយន្តការពីការនេះត្រួតពិនិត្យជាសាកលតាមកាលកំណត់លើកទី៣៕

## សូមអានបន្ថែម

- មជ្ឈមណ្ឌលអន្តរជាតិដើម្បីច្បាប់ដោយមិនយកកម្រៃ(អាយ.ស៊ី.អិន.អិល) ការពារសកម្មជនពីបណ្តឹងរំលោភបំពាន៖យុទ្ធសាស្ត្របណ្តឹងផ្លូវច្បាប់ប្រឆាំងនឹងការចូលរួមជាសាធារណៈ(២០២០) <https://www.icnl.org/post/report/slapps-in-the-global-south-report>។
- មជ្ឈមណ្ឌលធនធានធុរកិច្ចនិងសិទ្ធិមនុស្ស, យុទ្ធសាស្ត្របណ្តឹងផ្លូវច្បាប់ប្រឆាំងនឹងការចូលរួមជាសាធារណៈ៖ ករណីសិក្សានៅតំបន់អាស៊ីអាគ្នេយ៍ និងអនុសាសន៍សម្រាប់រដ្ឋាភិបាលធុរកិច្ចនិងសង្គមស៊ីវិល(២០២០) <https://media.business-humanrights.org/media/documents/files /documents/ SLAPPs_in_SEA_2020_Final_for_website.pdf>។

---

[5] របាយការណ៍ប្រចាំត្រីមាស ‘ស្ថានភាពសារព័ត៌មាននៅកម្ពុជា’ ខែមេសា ដល់ ខែមិថុនា ឆ្នាំ២០២៣ , https://www.camboja.net/wp-content/uploads/2023/07/Quarterly-Report-Apr-Jun-2023-EN.pdf ។

- អង្គការមាត្រា ១៩, របាយការណ៍សាកលនៃសេរីភាពខាងការបញ្ចេញមតិ ២០១៨/១៩: បណ្ដឹងព្រហ្មទណ្ឌប្រឆាំងនឹងការចូលរួមដើម្បីប្រយោជន៍សាធារណៈ(២០១៩)< https://www.article19.org/reader/global-expression-report-2018-19/global-analysis/global-analysis-2/civic-space/vexatious-litigation-against-public-participation/>។

---ចប់---

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

សមាគមអាដហុក
ADHOC

SOLIDARITY CENTER
AFL-CIO